ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៥០៩២ សហវ.-អសហក

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៧

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

**កម្មវត្ថុ:** ករណីសំណើសុំអនុម័តការចរចាថ្លៃ និងប្រគល់កិច្ចសន្យា ស្តីពីការងារស្ថាបនាផ្លូវក្រាលកៅស៊ូពីរជាន់ (DBST) ចំនួន ០១ខ្សែ ប្រវែង ៤ ២០០ម និងសាងសង់ស្លាកឈ្មោះផ្លូវចំនួន ០២កន្លែង ស្ថិតនៅខេត្តបន្ទាយមានជ័យ។

**យោង:**
- លិខិតលេខ ៤៥០៨ សហវ.អថ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- កំណត់ហេតុចរចាថ្លៃ នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧ របស់ គ.ល ក្រសួងអភិវឌ្ឍន៍ជនបទ
- លិខិតលេខ ០៩១៧/១៧ ក.អ.ជ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ របស់ក្រសួងអភិវឌ្ឍន៍ជនបទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ យល់ព្រមតាមសំណើរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងការប្រគល់កិច្ចសន្យា ជូននាយកដ្ឋានវិស្វកម្ម ក្រសួងការពារជាតិ ដើម្បីធ្វើការងារស្ថាបនាផ្លូវក្រាលកៅស៊ូពីរជាន់ (DBST) ចំនួន ០១ខ្សែ ប្រវែង ៤ ២០០ម ទទឹងខ្នងលើ ០៦ម ក្រាលចិញ្ចើមក្រួសក្រហម ០,៥ម សងខាង ស្ថាបនាលូមុខ បីទំហំ ១០០ស.ម ទទឹង ០៨ម ចំនួន ០១កន្លែង ស្លាកឈ្មោះផ្លូវចំនួន ០២កន្លែង និងជួសជុលលូមូលសរុបចំនួន ១១កន្លែង (លូមូលមុខបីទំហំ ១០០ស.ម ចំនួន ០៤កន្លែង លូមូលមុខពីរទំហំ ១០០ស.ម ចំនួន ០១កន្លែង លូមូលមុខបីទំហំ ៨០ស.ម ចំនួន ០២កន្លែង លូមូលមុខពីរទំហំ ៨០ស.ម ចំនួន ០៣កន្លែង និងលូមូលមុខមួយ ទំហំ ៨០ស.ម ចំនួន ០១កន្លែង) ភ្ជាប់ពីផ្លូវជាតិលេខ៥ត្រង់ភូមិសាលាក្រហម ទៅភូមិសំរោង ឃុំសំរោង ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ក្នុងតម្លៃសរុបចំនួន ២ ៤១៧ ០០០ ០០០រៀល (ពីរប៊ីលាន បួនរយដប់ប្រាំពីរលានរៀលគត់) ជាតម្លៃកិច្ចសន្យា។

ការជួលបន្តទៅឱ្យក្រុមហ៊ុនឯកជនត្រូវបានហាមឃាត់ជាដាច់ខាត។ បើអង្គភាពរដ្ឋណាមួយគ្មានលទ្ធភាពធ្វើខ្លួនឯងបានត្រូវដកហូតប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្តវិញ។ ក្នុងករណីប្រគល់ឱ្យអង្គភាពរដ្ឋមួយទៀតជាអ្នកអនុវត្តត្រូវស្នើសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុនសិន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបនិងមានវិធានការអនុវត្តបន្តឱ្យបានសមស្របតាមនីតិវិធីលទ្ធកម្មសាធារណៈតាមការគួរ ។

សូមឯកឧត្តមរដ្ឋមន្ត្រីទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

**<u>ចម្លងជូន:</u>**
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អគ្គនាយកដ្ឋានថវិកា
- នាយកដ្ឋានវិស្វកម្ម ក្រសួងការពារជាតិ
- នាយកដ្ឋានផ្លូវលំជនបទ
- សាលាខេត្តបន្ទាយមានជ័យ
- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តបន្ទាយមានជ័យ
- មន្ទីរអភិវឌ្ឍន៍ជនបទខេត្តបន្ទាយមានជ័យ
- ឯកសារ-កាលប្បវត្តិ